**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

លេខៈ ០០៥/១៧ សជណ អ.ជ.ប.គ.ញ. នសវង

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ សីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រេងរំអិល ជូនអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រាប់ប្រើប្រាស់ ក្នុងឆមាសទី២ ឆ្នាំ២០១៧

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមជំរាបជូនដំណឹងដល់បណ្តាក្រុមហ៊ុន (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន ឬសហគ្រាសទាំងអស់បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានអាស័យដ្ឋានស្ថិតនៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (ក្នុងទីស្តីការក្រសួងមហាផ្ទៃ " អគារ ៦ ") ចាប់ពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទំនាក់ទំនងលេខៈ <u>០៧៧ ២១១ ១១៥ និង០១២ ៥៣៣ ១១២)</u>។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១៥:០០នាទីរសៀល ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម (សាលប្រជុំតូច) តាមអាស័យដ្ឋានខាងលើ វេលាម៉ោង ១៥:០០ នាទីរសៀល ថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០១៧ ។

ក្រុមហ៊ុន ឬសហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន ឬសហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទំនាក់ទំនងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ជ.ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**និងជាប្រធាន...គបរប**

**កៅ_ខុនជាវី**

អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh